**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដោះស្រាយករណីក្រុមហ៊ុន យែនធើរេន អ៊ីភែរីល (ខេមបូឌា)

យោងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនបងប្អូនដែលជាកម្មករនិយោជិតនៃក្រុមហ៊ុន យែនធើរេន អ៊ីភែរីល (ខេមបូឌា) មានទីតាំងស្ថិតនៅភូមិត្រពាំងថ្លឹង៣ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ ដែលនិយោជកបានបិទទ្វាររត់ចោលថា យោងតាមស្មារតីនៃកិច្ចប្រជុំដោះស្រាយករណីក្រុមហ៊ុន យែនធើរេន អ៊ីភែរីល (ខេមបូឌា) កន្លងមក និងយោងតាមច្បាប់ស្តីពីការងារ ក្រសួងនឹងធ្វើការទូទាត់បើកប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងទៀតជូនបងប្អូនកម្មករនិយោជិត ចំនួន ៣ចំណុច ដោយប្រើថវិកាបុរេប្រទានរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

១. ប្រាក់ឈ្នួលខែចុងក្រោយដែលមិនទាន់បានបើក
២. ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់
៣. ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំ និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩។

សូមបងប្អូនកម្មករនិយោជិត មេត្តារង់ចាំការជូនដំណឹងបន្ថែមអំពីការបើកប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ពីអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញានាពេលឆាប់ៗខាងមុខនេះ។

ទន្ទឹមនឹងនេះ សូមបងប្អូនកម្មករនិយោជិតទាំងអស់ មេត្តាត្រៀមឯកសារមួយចំនួនដូចខាងក្រោម៖

១. បណ្ណសម្គាល់ខ្លួនកម្មករនិយោជិត (ច្បាប់ដើម) ឬកិច្ចសន្យាការងារ និងសៀវភៅការងារកម្មករនិយោជិត ឬបណ្ណបេឡាជាតិរបបសន្តិសុខសង្គម ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន។
២. បណ្ណបើកប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតម្នាក់ៗ (បើមាន)។

ក្នុងកំឡុងពេលនៃការរង់ចាំការជូនដំណឹងបន្ថែមនេះ សូមបងប្អូនដាក់ពាក្យស្វែងរកការងារធ្វើតាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដើម្បីរក្សាស្ថិរភាពនៃប្រាក់ចំណូល។

អាស្រ័យហេតុនេះ សូមបងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុន យែនធើរេន អ៊ីភែរីល (ខេមបូឌា) មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៥រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩